


# ផ្ទាំងគំនូរ គូរដោយដៃ ក្នុងខេត្តក្រចេះ
# ចងក្រងដោយៈ លោក  សាម រ៉ូប៊ឺតស៍

នេះគឺជាអត្ថបទប្រែសម្រួលចេញពីសៀវភៅខាងលើ ។ លោក ***ខៀវ និពន្ធ*** បានរៀបចំធ្វើការបកប្រែអត្ថបទនេះ។

ពត៌មានអំពីការជាវសៀវភៅនេះ គឺមាននៅក្នុងគេហទំព័រ: http://kratie.ghostsigns.co.uk.

អាស័យដ្ឋាន អ៊ីម៉ែលរបស់អ្នកនិពន្ធ គឺ: sam@ghostsigns.co.uk.

ទំព័រ 3

*ជូនចំពោះប្រជាជនខេត្ត ក្រចេះ និង ប្រទេសកម្ពុជា។ សូមអរគុណ សម្រាប់រយៈពេលពីរឆ្នាំដ៏អស្ចារ្យ។*

ទំព័រ 5

## អំពីអ្នកនិពន្ធ

លោក ***សាម រ៉ូប៊ឺតស៍*** គឺជាអ្នកថតរូប, អ្នកនិពន្ធ និង ជាអ្នក ស្រាវជ្រាវ មួយរូបដែលមានចំណាប់អារម្មណ៍ទៅលើផ្លាកយីហោ ដែល គូរ ដោយដៃ។ លោកបានថតយកនូវផ្លាកយីហោទាំងនេះ ដែល ផ្លាកយីហោបែបនេះភាគច្រើន នៅឯស្រុកកំណើត របស់គាត់ នា ទីក្រុង ឡុងដុង នោះ គឺត្រូវបានគេគូរនៅលើជញ្ជាំង។ លោកក៏បាន សរសេរ អត្ថបទជាច្រើន ទាក់ទងនឹងប្រធានបទ ដូចខាងលើនេះផងដែរ។

នៅក្នុងឆ្នាំ ២០១០, លោក ***សាម*** បានធ្វើដំណើរ មកកាន់ ប្រទេសកម្ពុជា ដើម្បីធ្វើជាអ្នកស្ម័គ្រចិត្តឲ្យអង្គការ VSO ។ នៅពេលទំនេរ លោកបានថតរូបផ្លាកយីហោ ដែលគូរដោយដៃ នៅក្នុងខេត្តក្រចេះ ដើម្បី ចងក្រងជាសៀវភៅនេះឡើង។

ផ្ទាំងគំនូរផ្លាកឃីហោគូរដោយដៃ ក្នុង ខេត្តក្រចេះ

កេហទំព័ររបស់លោក *សាម* អំពីផ្លាកឃីហោដែលគូរដោយដៃ គឺ www.ghostsigns.co.uk.

ទំព័រ 6

## សេចក្ដីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណដល់ភរិយារបស់ខ្ញុំបាទ ដែលបានគាំទ្រ និង ជំរុញចិត្តខ្ញុំឲ្យបង្កើតសៀវភៅនេះ ឡើង។ ខ្ញុំបាទក៏សូមថ្លែងអំណរ គុណ ផងដែរ ដល់អ្នករចនាម៉ូត និង អ្នកដែលបានផ្តល់ជាយោបល់ត្រឡប់ នៅលើសំណេររបស់ខ្ញុំបាទ។

ការគាំទ្រដ៏មានតម្លៃរបស់ លោក *ខៀវ និពន្ធ* និង លោក *ជី ឡេង៉ឆាយ* ដែលបានជួយបកប្រែផ្លាកឃីហោ ដល់ខ្ញុំបាទ និង ធ្វើឲ្យ មាន អត្ថបទជាភាសាខ្មែរនៅក្នុងសៀវភៅនេះ ។ សូមអរគុណដល់ លោកទាំងពីរចំពោះ ភាពអត់ធ្មត់ ទឹកចិត្តសប្បុរស និង ភាពសប្បាយ រីករាយ នៅក្នុងកិច្ចការនេះ។

ចំពោះក្របសៀវភៅដ៏រស់រវើក និងគួរឲ្យទាក់ទាញនេះវិញ, ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះជាងគំនូរ គឺ លោក *សាយ សុខឃាង៉*។ ការបកស្រាយរបស់លោកទៅលើយោបល់របស់ខ្ញុំជា អក្សរ ខ្មែរឆ្លាក់ ធ្វើឲ្យក្របសៀវភៅនេះ មានភាពលេចធ្លោ។ ឥឡូវនេះ រូបភាពដើម របស់ក្របសៀវភៅនេះ ត្រូវបានធ្វើជាស៊ុម និង ដាក់តាំង នៅក្នុងគេហដ្ឋានរបស់ខ្ញុំបាទ។

នៅទីបញ្ចប់នេះ ខ្ញុំបាទសូមថ្លែងអំណរគុណដល់ អ្នកគ្រប់គ្នា នៅក្នុងខេត្តក្រចេះ និង ប្រទេសកម្ពុជា ដែលបានធ្វើឲ្យ ពេលវេលារបស់ខ្ញុំនៅទីនេះ ក្លាយទៅជា បទពិសោធន៍មួយប្រកប ដោយ ភាព សប្បាយរីករាយ។ ខ្ញុំបាទនឹង ត្រឡប់ មកវិញម្តងទៀត ហើយ សង្ឃឹមថា អ្នកទាំងអស់គ្នា រួមជាមួយ នឹង ផ្លាកឃីហោមួយចំនួន ដែលមាននៅក្នុងសៀវភៅនេះ នឹង ស្ថិតនៅទីនេះ ដដែលដើម្បីរង់ចាំទទួលរូបខ្ញុំបាទ។

*សាម រ៉ូបឺតស៍*, ក្រចេះ, ខែ កញ្ញា ឆ្នាំ ២០១២

ទំព័រ 9

## មាតិកា



| | |
|---|---|
| បុព្វកថា | 10 |
| សេចក្តីផ្តើម | 12 |
| ផ្លាកយីហោនៅក្នុងប្រទេសកម្ពុជា | 16 |
| ជាងគំនូរខ្មែរ | 32 |
| ការរចនាក្របសៀវភៅ | 40 |
| អក្សរខ្មែរ | 44 |
| ការស្គាល់ប្រទេសកម្ពុជាតាមរយៈផ្លាកយីហោ | 48 |
| ពត៌មានសាធារណៈ | 58 |
| ហាងកែសម្ផស្ស និង កាត់សក់ | 70 |
| សុខភាព | 86 |
| ចំណីអាហារ និង សិល្បៈ | 92 |
| កាត់ដេរ | 96 |
| ការដឹកជញ្ជូន | 102 |
| សត្វពាហនៈ | 112 |
| បច្ចេកវិទ្យា | 120 |
| នៅតាមផ្លូវក្នុងប្រទេសកម្ពុជា | 132 |
| ការបកប្រែ | 134 |
| អំណានបន្ថែម | 138 |



ទំព័រ 11

## បុព្វកថាដោយលោក Joel Montague

ពិពណ៌ផ្លាកយីហោ ទីផ្សារនៅក្រុងបូស្តុន សហរដ្ឋអាមេរិច បានបង្ហាញនូវផ្ទាំងគំនូរផ្លាកយីហោហាងរបស់កម្ពុជាជាច្រើន។ ជនជាតិខ្មែរមួយរូបដែលរស់នៅសហរដ្ឋអាមេរិចបាននិយាយថា ផ្ទាំងគំនូរផ្លាកយីហោទាំងនោះបានធ្វើឲ្យគាត់នឹកឃើញពី កុមារភាពរបស់គាត់នៅក្នុងប្រទេសកម្ពុជា។

២០ ឆ្នាំកន្លងទៅ. ផ្លាកយីហោភាគច្រើន នៅក្នុងប្រទេសកម្ពុជា ត្រូវបានគេគូរ។ ឥឡូវនេះ ផ្លាកយីហោទាំងនេះ ជារឿយៗត្រូវបានធ្វើឡើងដោយការឆ្នៃម៉ូដ និង ប្រើបច្ចេកវិទ្យាបោះពុម្ព។ផ្លាកយីហោថ្មីៗជាច្រើន ធ្វើការផ្សព្វផ្សាយពីផលិតផលបរទេស ព្រមទាំងពីស្ថាបន័ដែលផលិតវា។ ជាងគំនូរត្រូវតែប្រឹងរត់ឲ្យទាន់សម័យកាលនៃការផ្លាស់ប្តូរនេះ។

ផ្លាកយីហោនៅក្នុងសៀវភៅនេះ និង នៅទូទាំងប្រទេសកម្ពុជា គឺមានលក្ខណៈសប្បាយរីករាយ និង ទាក់ភ្នែក។ រូបគំនូរផ្លាកយីហោទាំងនោះ មានលក្ខណៈសិល្បៈ តាមរបៀបជាច្រើន។ ការកត់ត្រាទុកជាឯកសារអំពីផ្ទាំងគំនូរផ្លាកយីហោ ដូចក្នុងសៀវភៅនេះ គឺជាការសំខាន់ ដោយវានឹងជួយដល់យើងឲ្យចងចាំបាននូវផ្លាកយីហោទាំងនេះនៅក្នុងពេលអនាគត នៅពេលដែលផ្លាកយីហោរបៀបនេះ លែងមានតទៅទៀត។

ផ្ទាំងគំនូរផ្លាកយីហោគូរដោយដៃ ក្នុង ខេត្តក្រចេះ

*លោក ចូអែល មុនតាហ្គ (Joel Montague) គឺជាអ្នកធ្វើការផ្នែកអភិវឌ្ឍន៍មួយរូបនៅក្នុងប្រទេសកម្ពុជា ទសវត្សរ៍ ឆ្នាំ ១៩៩០។ លោកបានសន្សំ ផ្ទាំងគំនូរផ្លាកយីហោហាងខ្មែរ, បណ្ណ័ប្រៃសណីយ៍, និង រូបគំនូរព្រះពុទ្ធ សាសនាជាច្រើន។ លោកបានសរសេរសៀវភៅជាច្រើនអំពី ការសន្សំរបស់គាត់ និង បានដាក់តាំងបង្ហាញនៅក្នុងពិពណ៌ជាច្រើន។ រូបភាពនៅទំព័រទី ៨ គឺ មកពីរូបភាពមួយដែលលោកសន្សំ។*

ទំព័រ 13

## សេចក្តីផ្តើម

មានផ្ទាំងគំនូរផ្លាកយីហោដែលគូរដោយដៃជាច្រើននៅតាមផ្លូវ របស់ប្រទេសកម្ពុជា។ចំពោះជនបរទេសផ្ទាំងគំនូរផ្លាកយីហោទាំងនោះ គឺគួរឲ្យចាប់អារម្មណ៍ ពីព្រោះវាខុសប្លែកពីផ្លាកយីហោនៅក្នុងប្រទេសដទៃទៀត។ នៅពេលខ្ញុំរស់នៅខេត្តក្រចេះ រយៈពេលពីរឆ្នាំ ខ្ញុំបានថតយកផ្លាកយីហោដ៏គួរឲ្យចាប់អារម្មណ៍ទាំងនេះ។ ផ្ទាំងគំនូរផ្លាកយីហោទាំងនោះ ត្រូវបានបង្ហាញជូននៅក្នុងសៀវភៅនេះ ហើយវាក៏ស្រដៀង គ្នានឹងផ្ទាំងគំនូរផ្លាកយីហោនៅតាមបណ្តាខេត្តនានាក្នុងប្រទេសកម្ពុជាផងដែរ។

ខេត្តក្រចេះ មានការអភិវឌ្ឍន៍យ៉ាងឆាប់រហ័ស។ នៅក្នុងរយៈពេល២ ឆ្នាំចុងក្រោយនេះ យើងមានសំណង់ផ្សារថ្មី,ទឹកស្អាត, ការផ្គត់ផ្គង់អគ្គិសនី និង ផ្លូវថ្នល់ថ្មីៗជាច្រើន។ខេត្តក្រចេះ ល្បីល្បាញដោយសារមានសត្វផ្សោតដែលកម្រ និង អាគារចាស់ៗជំនាន់បារាំង។ វប្បធម៌រីករាយ ប្រជាជនរាក់ទាក់ និង ទន្លេដ៏ស្រស់ស្អាត បានធ្វើឲ្យរយៈពេលពីរឆ្នាំរបស់ខ្ញុំនៅទីនេះ មានភាពសប្បាយរីករាយ។

ចំណាប់អារម្មណ៍របស់ខ្ញុំបាទពីមុន អំពីផ្ទាំងគំនូរផ្លាកយីហោ នៅប្រទេសអង់គ្លេស បានធ្វើឲ្យខ្ញុំ ចាប់អារម្មណ៍ផ្ទាំងគំនូរផ្លាកយីហោនៅទីនេះ ព្រមទាំងភរិយារបស់ខ្ញុំបាទបានលើកទឹកចិត្តខ្ញុំឲ្យចងក្រងជាសៀវភៅនេះឡើង។ សព្វថ្ងៃនេះ ផ្ទាំងគំនូរផ្លាកយីហោគូរដោយដៃ មិនសូវមានប្រជាប្រិយ៍ភាព ដូចផ្ទាំងគំនូរបោះពុម្ពថ្មីៗទេ។ ប្រវត្តិនៃផ្ទាំងគំនូរផ្លាកយីហោដែលគូរដោយដៃ គឺទាក់ទងទៅនឹងប្រវត្តិសាស្ត្រ ប្រទេសកម្ពុជា ហើយ សៀវភៅនេះ នឹងពិភាក្សាអំពីទំនាក់ទំនងនេះ។

ផ្ទាំងគំនូរផ្លាកយីហោទាំងនេះ មានភាពស្រស់ស្អាត និង បានគូរដោយជាងគំនូរដែលមានជំនាញ ប៉ុន្តែតួនាទីរបស់ជាងគំនូរទាំងនេះ កំពុងផ្លាស់ប្តូរហើយ។ ខ្ញុំសង្ឃឹមថាជាងគំនូរ ដូចជាលោក **សាយ សុខឃាជ័** នៅខេត្តក្រចេះ នឹងជួយរក្សាឲ្យផ្ទាំងគំនូរផ្លាកយីហោមានជីវិតរស់នៅ ក្នុងប្រទេសកម្ពុជា។ ខ្ញុំបាទសង្ឃឹមថា ប្រជាជននឹងបន្តគូសនូវអក្សរផ្លាក់របស់ខ្មែរដ៏ស្រស់ស្អាត។ ខ្ញុំក៏សង្ឃឹមផងដែរថាលោកអ្នកនឹងចូលរួមជាមួយយើងខ្ញុំនៅក្នុងពិធីនៃផ្ទាំងគំនូរផ្លាកយីហោគូរដោយដៃ នៅក្នុងខេត្ត ក្រចេះ និង ក្នុងប្រទេសកម្ពុជា។

ទំព័រ 13

## ការប្រើប្រាស់សៀវភៅនេះ

សៀវភៅនេះ ជាដំបូងគឺបង្ហាញឲ្យស្គាល់អំពី ផ្ទាំងគំនូរផ្លាកយីហោដែលគូរដោយដៃ រួមជាមួយនឹងវិចិត្រករដែលគូររូបទាំងនោះ។ ទំព័រយោងសម្រាប់រូបភាពទាំងនោះ គឺ ស្ថិតនៅក្នុងវង់ក្រចកឃ្នាប ឧទាហរណ៍: [20]។ បន្ទាប់មកទៀត គឺជារូបថតរបស់ផ្លាកយីហោ ទៅតាម មុខរបរដែលផ្សព្វផ្សាយ។ រូបទាំងនេះត្រូវបានណែនាំឲ្យអ្នកអាន បានស្គាល់ អំពីផ្លាកយីហោ, ជីវភាពរស់នៅរបស់បងប្អូនប្រជាជនកម្ពុជា ព្រមទាំងវប្បធម៌

របស់គេ តាមរយៈការសង្កេតរបស់អ្នកនិពន្ធ។កេហទំព័រ សម្រាប់ការគាំទ្រដល់សៀវភៅនេះ គឺស្ថិតនៅ *http://kratie.ghostsigns.co.uk*. ។

ទំព័រ 17

## ផ្ទាំងគំនូរផ្លាកយីហោក្នុងប្រទេសកម្ពុជា

*"ជារឿយៗ មានលក្ខណៈកំប្លុកកំប្លែង,ជានិច្ចកាលមានមន្តស្នេហ៍, ហើយ ជួនកាល មិនមានលក្ខណៈជំនាញនៅក្នុងការគូរ។"*
លោក រ៉ូប៊ឺត ចនរ៍ (Robert Joiner) អ្នកថតរូប កាសែត

ផ្ទាំងគំនូរ គូរដោយដៃនៅក្នុងប្រទេសកម្ពុជា មានអតីតកាល ដ៏គួឲ្យចាប់អារម្មណ៍ និង អនាគតមួយដែលមិនច្បាស់លាស់។

## ប្រវត្តិសង្ខេបមួយ

នៅក្នុងសម័យខ្មែរក្រហម មិនមានមុខជំនួញជួញដូរ ហើយ ក៏មិនមាន ការផ្សាយពាណិជ្ជកម្មដែរ។ តែមុននេះ គឺមានផ្ទាំងគំនូរផ្លាក យីហោជាច្រើន។ បន្ទាប់ពីវៀតណាមបានមកដល់នៅក្នុងឆ្នាំ ១៩៧៩, ផ្ទាំងប៉ាណូនានា បានអនុញ្ញាតិឲ្យរដ្ឋាភិបាលធ្វើទំនាក់ទំនង នូវសារនានា របស់ខ្លួន។ គឺដោយសាររឿងនេះហើយ ដែលធ្វើឲ្យផ្ទាំងគំនូរផ្លាក យីហោ ដែលគូរដោយដៃ បានវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ។

អង្គការក្រៅរដ្ឋាភិបាល ក៏បានប្រើនូវផ្ទាំងប៉ាណូ ដើម្បីផ្តល់ ជា ដំបូន្មាន លើបញ្ហាផ្សេងៗ ដូចជាការរួមភេទ ប្រកបដោយសុវត្ថិភាព, ការគ្រប់គ្រងកាកសំណល់ជាដើម។ផ្ទាំងប៉ាណូចាស់ៗ ច្រើនស្ថិតនៅ ក្នុងទីប្រជុំជន ចំណែកផ្ទាំងប៉ាណូថ្មីៗ ភាគច្រើននៅតំបន់ជនបទ។
កិច្ចព្រមព្រៀង សន្តិភាព ទីក្រុងប៉ារីសក្នុង ឆ្នាំ ១៩៩១ បាននាំមក នូវស្ថិរភាព និង បានផ្តល់នូវមូលនីធិសម្រាប់ការធ្វើពាណិជ្ជកម្ម និង ការ ផ្សព្វផ្សាយពាណិជ្ជកម្ម។ លោក ចូអែល ម៉ុនថាហ្គ័( Joel Montague) ដែលជាអ្នកសន្សំផ្ទាំងគំនូរផ្លាកយីហោ បាននិយាយថាការវិល ត្រឡប់មក វិញនូវ ផ្លាកយីហោ នៅពេលនេះ *“បានបង្ហាញឲ្យយើងឃើញ ពីអ្វីមួយ របស់ ប្រទេសមួយដែលកំពុងងើបឡើងវិញ*។

ការផ្សព្វផ្សាយពាណិជ្ជកម្ម នៅពេលនេះ គឺមានស្ទើរគ្រប់ទី កន្លែង ក្នុងប្រទេសកម្ពុជា។ ការផ្សព្វផ្សាយនេះ ដំបូងបានចាប់ផ្តើម ពីផ្ទាំង គំនូរផ្លាកយីហោដែលគូរដោយដៃ។ឥឡូវនេះ ផ្លាកយីហោដែលបោះពុម្ព កំពុងមានប្រជាប្រិយ៍ភាពជាង ក៏ព្រោះតែការមកដល់នូវបច្ចេកវិទ្យាថ្មីៗ។ ជាងគំនូរមួយរូបនៅខេត្តកំពង់ចាម ឈ្មោះលោក *សុខ សារ៉ាត* បាន និយាយថា *“វិធីសាស្រ្តថ្មីនេះ គឺរហ័សជាងមុន ”*។ ប្រាក់បៀវត្សរ៍ កាន់តែខ្ពស់ នៅក្នុងប្រទេសកម្ពុជា ក៏ធ្វើឲ្យផ្ទាំងគំនូរផ្លាក យីហោ ដែល គូរដោយដៃ កាន់តែថ្លៃជាង ផ្លាកយីហោបោះពុម្ពផងដែរ។

គ្រីស្ទីណា នូឡាត( Christina Nualart) ជាវិចិត្រករមួយរូប ដែល មាន ទីលំនៅក្នុងប្រទេសវៀតណាម គិតថាមនុស្សឥឡូវចូលចិត្ត ផ្លាកយីហោ បោះពុម្ពជាង ពីព្រោះ *“វាមានលក្ខណៈទាន់សម័យ ”*។នេះ គឺ ជា ការពិតព្រោះថា ប្រជាជនកម្ពុជាឲ្យតម្លៃលើរបស់ដែល ស្អាត និង ទាន់សម័យ។ ចំណូលចិត្តទាំងនេះ ជះឥទ្ធិពលដល់ការងាររបស់ ជាង គំនូរ ផងដែរ។

ផ្ទាំងគំនូរផ្លាកយីហោដែលគូរដោយដៃ អាចនឹងមាន ប្រជា ប្រិយ៍ភាព ឡើងវិញ នៅពេលអនាគតដូចគ្នា ទៅនឹងសហរដ្ឋអាមេរិច និង ចក្រភព អង់គ្លេសនាពេលបច្ចុប្បន្ននេះ។ តែទោះជាយ៉ាងណាក្តី សម្រាប់

ផ្ទាំងគំនូរផ្លាកយីហោគូរដោយដៃ ក្នុង ខេត្តក្រចេះ

ពេលបច្ចុប្បន្ននេះ វាហាក់ដូជាថា ផ្ទាំងគំនូរផ្លាកយីហោ គូរដោយដៃ នៅ ក្នុងប្រទេសកម្ពុជា អាចនឹង ក្លាយទៅជាផ្នែកមួយនៃប្រវត្តិសាស្ត្រ ក្នុងពេល ឆាប់ៗ ម្តងទៀត។

## ប្រភេទផ្ទាំងគំនូរផ្លាកយីហោ

ផ្ទាំងគំនូរផ្លាកយីហោនៅក្នុងប្រទេសកម្ពុជា គឺធ្វើពីវត្ថុខុសៗគ្នា ។ ប្រភេទដែលគេនិយម ជាងគេ គឺផ្លាកយីហោបញ្ឈរ ដែល ធ្វើពីលោហ: ឬ ក្តារបន្ទះ [20, 26].ខ្លះទៀត ព្យួរនៅតាមអាគារ, ដើមឈើ និង តាមបង្គោល ខ្សែភ្លើង [22, 26-7]. ផ្ទាំងគំនូរផ្លាកយីហោភាគច្រើន គឺ ត្រូវបានគូរទាំង សង្ខាង [95]. ផ្លាកយីហោនៅមុខហាងជាទូទៅ ស្ថិតនៅពី លើ ច្រកចូល [19] តែមានផ្លាកមួយនៅ ក្រចេះ គឺដាក់ជាប់នឹងទ្វារតែម្តង [29].ផ្លាកយីហោ មុខហាងមួយ គូរនៅលើសន្លឹកសង្ក័សី ដាក់ពី លើ ច្រកចូលតែម្តង [27] ។ប្រភេទខ្លះទៀតធ្វើពីក្រណាត់ តង់ [28]ហើយ ផ្លាក យីហោខ្លះទៀត គូរនៅលើជញ្ជាំង [22]. ការព្យួរសំបកកៅស៊ូកង់ បង្ហាញ ពីការជួសជុលយានយន្ត, ជួនកាលមានបន្ថែមអត្ថបទតិចតួច [22-3].។

## ការផលិតផ្លាកយីហោ

ផ្លាកយីហោ ត្រូវបានផលិតឡើងពី ថ្នាំពណ៌ប្រេង។ ជួនកាលគេ ប្រើថ្នាំកំប៉ុងបាញ់ ហើយជួនកាលទៀត គេប្រើរូបថត ឬ អក្សរបិតភ្ជាប់ ទៅ នឹង ផ្លាកយីហោតែម្តង។ការបិទភ្ជាប់បន្ថែមបែបនេះ ជាធម្មតាមិន សូវ មានភាព រឹងមាំទេ ហើយអាចខូចបានយ៉ាងងាយទៀតផង [78].។

ជួនកាលផ្ទាំងគំនូរផ្លាកយីហោ ត្រូវបានយកមក លាបថ្នាំ ឡើង វិញ។ នេះអាចបង្កើតជាផលវិបាកពេលក្រោយ ដោយមកពី ថ្នាំលាប ថ្មី បាន ហើរពណ៌ ហើយបង្ហាញនូវផ្ទាំងរូបភាពផ្លាកយីហោចាស់ [96, 129]។

## ខ្លឹមសាររូបភាព

ខ្លឹមសាររូបភាព តំណាងឲ្យមុខជំនួញខុសៗគ្នា ឧទាហរណ៍ រូបម៉ូតូ តំណាងឲ្យ ហាងជួសជុលម៉ូតូ ដែលនេះ គឺអាចជួយដល់ អ្នក ដែល មិនចេះអាន ប៉ុន្តែមានផ្លាកយីហោមួយដែលមាន លក្ខណ:ច្រឡូកច្រឡំដែរ ព្រោះផ្លាកយីហោនោះ មានរូបទន្សាយលើកម្ទូប[26].។

ខ្លឹមសាររូបភាព ជាធម្មតាគឺត្រូវបានចម្លង ពីរូបថតផ្នែក ទាំង សង្ខាង នៃ ផ្លាកយីហោតែមួយ [83],ប៉ុន្តែក៏មានផ្លាកយីហោ ដែល មានលក្ខណ:ខុសគ្នាទាំងស្រុងផងដែរ។ ដើម្បីជៀសវាងនូវ ផ្លាកយីហោ ដូចគ្នា សម្រាប់ការប្រកួតប្រជែងក្នុងមុខរបរនោះ គេបានប្រើគំរូ និង ពណ៌ខុសៗគ្នា ដើម្បីធ្វើឲ្យផ្លាកយីហោនិមួយៗខុសគ្នា [80-1].។

ផ្លាកយីហោដែលគូរដោយជាងគំនូរអាជីព មានខ្លឹមសារ បក ស្រាយប្រកបដោយគុណភាពល្អជាង។ តែ ទោះជាយ៉ាងណាក្តី ផ្លាក យីហោ ដែលគូរដោយជាងមិនមែនអាជីព ក៏មានរូបភាព ទាក់ទាញ ដល់ជនបរទេសផងដែរ។

## ផ្លាកយីហោ ជាសិល្ប:

មនុស្សខ្លះគិតថា ផ្លាកយីហោ គឺជាទម្រង់មួយនៃ សិល្ប:។ លោក **ចូអែល ម៉ុងតាហ្គ**(Joel Montague ) ដែលបានដាក់តាំង ផ្លាកយីហោ ខ្លះៗ នៅក្នុងពិពណ៌មួយ នៅឯសហរដ្ឋអាមេរិច គឺបានបកស្រាយ ដូចគ្នានឹងគំនិតខាងលើដែរ ទៅតាមផ្ទាំងគំនូរមួយៗដែលបានបង្ហាញ។ លោក បាន និយាថា *"វាជាការផ្សាយពាណិជ្ជកម្ម។ប៉ុន្តែវាជាទម្រង់ មួយ នៃ សិល្ប:"*។ ជនបរទេសជា ច្រើនផ្សេងទៀត បានឯកភាពជាមួយលោកដែរ។ ប្រជាជនកម្ពុជា មានទស្សន:មួយផ្សេង។ ជាងគំនូរឈ្មោះ **ស្វាយ គោន** បាន និយាយថា "

*វាមិនមែនជាសិល្បៈទេ ពីព្រោះផ្ទាំងគំនូរផ្លាកឃីហោ ទាំងនោះ ត្រូវបានធ្វើឡើងដើម្បីប្រាក់ ហើយអតិថិជន គឺជាអ្នក សម្រេច ឲ្យគូរបែបណា".* លោក **សាយ សុខឃាជ** ដែលជាងគំនូរម្នាក់ នៅខេត្ត ក្រចេះ បាននិយាយថា ផ្លាកឃីហោទាំងនេះ គឺជាការងាររបស់គាត់ ហើយ លោកបង្កើតសិល្បៈរបស់លោក ទៅតាមពេលវេលា របស់លោកផ្ទាល់។

សម្រាប់ប្រជាជនកម្ពុជា ភាពខុសគ្នាជាគន្លឹះ គឺថាតើរបស់ មួយ ត្រូវ បានបង្កើតឡើងពីទឹកចិត្ត ឬ ធ្វើឡើង ដើម្បីប្រាក់។

## ផ្ទាំងគំនូរផ្លាកឃីហោក្នុងខេត្តក្រចេះ

ផ្ទាំងគំនូរផ្លាកឃីហោជាច្រើននៅក្នុងសៀវភៅនេះ គឺស្ថិតនៅ ក្នុងខេត្តក្រចេះ ប៉ុន្តែវាស្រដៀងគ្នាទៅនឹង ផ្ទាំងគំនូរផ្លាកឃីហោនៅ ក្នុង ខេត្ត ផ្សេងៗទៀតផងដែរ។ភាពខុសគ្នា កើតចេញមកពីជាងគំនូរ ដែល ធ្វើការ នៅកន្លែងផ្សេងៗគ្នា។ ជាងគំនូរម្នាក់ៗ មានបែបបទរបស់ខ្លួនផ្ទាល់ ដែលចំណុចនេះ គេអាចមើលឃើញនៅក្នុងផ្ទាំង គំនូរផ្លាកឃីហោ នៅក្នុង តំបន់របស់ពួកគេ។

ផ្លាកឃីហោជាច្រើននៅក្នុងសៀវភៅនេះ ត្រូវបានជំនួស ដោយ ផ្លាក ឃីហោដែលបោះពុម្ព ហើយ នៅក្នុងពេលអនាគត់ ផ្លាកឃីហោ ច្រើ នថែម ទៀតនឹងត្រូវបានជំនួសដោយការបោះពុម្ព។ សៀវភៅនេះ កត់ត្រា ពីការផ្សាយពាណិជ្ជកម្មដ៏ល្អរបស់ខ្មែរ ដែលកំពុង បាត់បង់ ជា បណ្តើរៗ។

ទំព័រ 33

## ជាងគំនូរខ្មែរ

*"ខ្ញុំគ្រាន់តែបន្តប្រើប្រាស់នូវជក់ និង ក្តីស្រម័យរបស់ខ្ញុំ ហើយ សង្ឃឹម ថានឹងមានអ្នកណាម្នាក់ត្រូវការ ជានិច្ចនូវអ្វីដែលខ្ញុំអាចផ្តល់ជូន។ តើមា នអ្វីត្រូវធ្វើទៀតទេ?"*
លោក លឹម គៀវ, ជាងគំនូរនៅភ្នំពេញ

ប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ក៏បានជះឥទ្ធិពល ដល់ជាង គំនូរផងដែរ។ ប្រវត្តិរបស់ពួកគេ គឺ ស្រដៀងគ្នានឹងវិចិត្រករដទៃទៀត ដែល មានគំនាបសង្កត់បន្ថែមឲ្យ ធ្វើការផ្លាស់ប្តូរនូវចំណូលចិត្ត ដែល ធ្លាប់ មាន។

## សិល្បៈក្នុងប្រទេសកម្ពុជា

ក្រោយទទួលបានឯករាជ្យពីប្រទេសបារាំង ក្នុងឆ្នាំ ១៩៥៣, វិស័យ សិល្បៈទទួលបានការគាំទ្រយ៉ាង ខ្លាំង ជាពិសេស ពីរាជវង្សានុវង្ស។ តែទោះ ជាយ៉ាងនេះក្តី, បដិវត្តខ្មែរក្រហម បាននាំឲ្យមាន សោកនាដ្យកម្ម ជាថ្មីម្តងទៀត។

ពួកខ្មែរក្រហម បានកំណត់គោលដៅសិល្បករ ដើម្បីសម្លាប់។ សិល្បករ/ការិនី ជាង ៩០% ត្រូវបាន សម្លាប់ ដែលរួមមាន អ្នកនិពន្ធ, ផលិតករភាពយន្ត និង អ្នកចម្រៀង ដូចជា ***រស់ សេរីសុទ្ធា*** និង
***ស៊ិន ស៊ីសាមុត*** ជាដើម។

***សំអាជ សម***, ដែលជាតន្ត្រីករមួយរូប ដែលកំពុងរស់ នៅ សហរដ្ឋអាមេរិច បានសរសេរថា " មិនមានការអប់រំសិល្បៈទេ គឺមាន តែសារនយោបាយប៉ុណ្ណោះដែលសំខាន់។មិនមានវិចិត្រករអាជីពទេ ហើយ ក៏មិនមានសេរីភាព នៃ ការច្នៃប្រឌិតដែរ" ខ្មែរក្រហម ក៏បានបិទទ្វារ សកលវិទ្យាល័យវិចិត្រសិល្បៈផងដែរ។

ផ្ទាំងគំនូរផ្លាកយីហោគូរដោយដៃ ក្នុង ខេត្តក្រចេះ

វិចិត្រករដែលរស់រានមានជីវិតនៅពេលនេះ គឺមានរឿងរ៉ាវ ផ្ទាល់ ខ្លួន របស់គេ។ លោក វ៉ាង៉ ណាត, ជាងគំនូរមួយរូប ដែលនៅ រស់រានមានជីវិត ក្នុងចំណោមអ្នកទោស ៧ នាក់ ពីមន្ទីរ ស ២១ (ទួលស្លែង) ។ ឌុច ដែលជាប្រធានគុកទួលស្លែងបានសរសេរថា , *"ទុកជីវិតជាងគំនូរ"* នៅក្នុងបញ្ជីអ្នកទោសត្រូវសម្លាប់របស់គេ។ ជំនាញ សិល្បៈ បានជួយជីវិតរបស់គាត់ ដោយគាត់ត្រូវបានគេប្រើឲ្យគូររូប ប៉ុល ពត។ ក្រោយឆ្នាំ ១៩៧៩ គាត់បានគូររូបភាពជាច្រើនអំពីអំពើឃោរឃៅ និង ការធ្វើទារុណកម្ម ដែលគាត់បានឃើញនៅក្នុងមន្ទីរ ស ២១។

សិល្បៈក៏បានជួយសង្គ្រោះជីវិតដល់ លោក **អាន ឈឿនប៉ុន** ផងដែរ ដែលពេលនោះ គាត់បានផ្តុំក្តួយឲ្យ ពួកដែលចាប់ ខ្លួនលោក ស្តាប់។ ឥឡូវនេះ លោកបានបង្កើតក្រុមសិល្បៈជីវិតខ្មែរ ដើម្បីជួយ ដល់វិចិត្រករដែលនៅរស់រានមានជីវិត ឲ្យចែករំលែកនូវជំនាញរបស់ពួកគេ។ ពួកគេចង់ឲ្យសិល្បៈ ក្នុងប្រទេសកម្ពុជារស់រានមានជីវិតឡើងវិញ ដោយរួម ជាមួយនឹងអង្គការនានាជាច្រើនផងនោះ ពួកគេទទួលបាននូវការរីកចំរើនយ៉ាងច្រើន។ តែទោះជាយ៉ាងនេះក្តី ក៏វា ជា ការលំបាកនឹងមានសុទិដ្ឋិនិយម អំពីអនាគតរបស់ជាងគំនូរណាស់។

## ការបណ្តុះបណ្តាលជាង គំនូរ

គំនូរ និង ជំនាញរបស់គេ ក៏បានបាត់បង់ផង ដែរនៅ កំឡុង ពេលនៃរបបខ្មែរក្រហម។ ជាងគំនូរខ្លះអាចបង្រៀនកូនចៅរបស់ខ្លួន ឧទាហរណ៍ ដូចជា លោក ***សុខ សារ៉ាត*** មកពីខេត្តកំពង់ចាម ជាដើម។ ជួនកាលវិចិត្រករខ្លះចេញមកពីជំនាញគូរផ្សេង ហើយបានមកចាប់ផ្តើម ការគូរ គំនូរផ្លាកយីហោនេះ ឧទាហរណ៍ដូចជាលោក អោ យុទ្ធា ដែលជា អតីតជាងគំនូរ តួកកំប្លែងជាដើម។ ជាងគំនូរអាជីពភាគច្រើន គឺបាន រៀន គូរដោយខ្លួនឯង ឧទាហរណ៍ ដូចជាលោក **លឹម គៀវ** ដែលបាន និយាយថា, *"ខ្ញុំរៀនជំនាញនេះជាធម្មតាដោយមិនដឹងខ្លួន ហើយ អភិវឌ្ឍន៍ វា ដោយខ្លួនឯង"*។

តម្រូវការផ្ទាំងគំនូរផ្លាកយីហោកំពុងមានការថយចុះ ហើយក្នុង ពេល ឆាប់ៗនេះ ជំនាញផ្សេងនឹងមានសារសំខាន់ជាង។ ជាការល្អ ដែល អង្គការនានា ដូចជា អង្គការជីវិតសិល្បៈខ្មែរ ដែលត្រូវថែរក្សា នូវ ជំនាញ ទាំងនោះឲ្យរស់រានមានជីវិត ដើម្បីរក្សាបាននូវផ្ទាំងគំនូរផ្លាក យីហោ ចម្រុះ ពណ៌ ជួយតុបតែងលំអរដងផ្លូវនានារបស់ប្រទេសកម្ពុជា។

## ដំណើរការ ផ្លែម៉ូតផ្ទាំងគំនូរ

ជាងគំនូរត្រូវបានគេនិយាយប្រាប់គ្រួសៗអំពីគម្រូជាក់លាក់ណាមួយ ឬ ដោយការរៀបរាប់ពីអ្វីដែលម៉ូយចង់បាន មុននឹងជាង គំនូរ ចាប់ ផ្តើមគូររូបគំនូរព្រាងឲ្យអតិថិជនមើល។ រូបគំនូរដែលប្រើធ្វើជាក្របសៀវភៅនេះ គឺត្រូវបានធ្វើតាមរបៀបទី២ [40-3]។

បន្ទាប់មកទៀត ជាងគំនូរចាប់ផ្តើមបែងក្រឡាឆ្លាក់អក្សរ, ជួន កាលប្រើ គំរូអក្សរដែលមានស្រាប់។ បន្ទាត់បែងក្រឡានេះ អាចនៅ មើល ឃើញ លើផ្ទាំងគំនូរផ្លាកយីហោដែលធ្វើរួចជាច្រើន [37].បន្ទាប់ មក ផ្ទាំងគំនូរទាំងនោះត្រូវបានរៀបដាក់តាម ជាន់ថ្នាក់ ដើម្បី ឲ្យ ស្រទាប់ ថ្នាំស្ងួត។ នៅទីបញ្ចប់ ផ្ទាំងគំនូរផ្លាក យីហោត្រូវបាន ត្រៀម រៀប ចំធ្វើស៊ុម។

## ប្រវត្តជាងគំនូរម្នាក់

លោក ***សាយ សុខឃាង*** បានបើកកន្លែងគូរគំនូរផ្លាកយីហោ យូរជាងគេនៅខេត្តក្រចេះ។ លោកបានគូរ រូបភាព សម្រាប់ក្រប សៀវភៅ នេះ ព្រមទាំងបានជជែកជាមួយខ្ញុំអំពីជីវិត និង ការងាររបស់លោក។

លោក **សុខឃាង** កើតនៅ កំពង់ចាម ក្នុង ឆ្នាំ ១៩៨៤។ លោកមានចិត្តស្រឡាញ់សិល្បៈតាំងពីនៅក្មេងហើយ លោក រៀនពូកែ លើមុខវិជ្ជាគូរគំនូរនេះ កាលលោកនៅរៀន។ លោកបានប្រាប់ខ្ញុំថា*"ខ្ញុំតែងតែគូររូបផ្សេងៗ ជានិច្ច"* ។

លោក **សុខ ឃាង** បានជួបនឹងគ្រូរបស់លោក ឈ្មោះ ស ប៊ុនធឿន នៅក្នុងឆ្នាំ ២០០០។ លោក **ប៊ុនធឿន** ជាអ្នកខេត្តបាត់ដំបង បានផ្លាស់មករស់នៅខេត្តកំពង់ចាម បន្ទាប់ពីស្នាក់នៅក្នុងជំរុំ សាយធូ ប្រទេសថៃ ។ ការរៀនគូររបស់លោក **សុខ ឃាង** គឺប្រើខ្មៅដៃ ដើម្បី គូររូបមុខមនុស្ស និង គូរតាមរូបភាព ពីក្នុងរូបថតនានា។ បន្ទាប់មកគាត់បានចាប់ផ្តើមផាត់ពណ៌ ទៅលើរូបគំនូរទាំងនោះ។

នៅក្នុងឆ្នាំ ២០០២, លោក **សុខឃាង**បានផ្លាស់ មកនៅ ខេត្តក្រចេះ ហើយបានចាប់ផ្តើមមុខរបរគូរគំនូរ ឈ្មោះ ជក់រចនា របស់ លោក ជាមួយនឹង មិត្តភក្តិម្នាក់ឈ្មោះ **ជួន ប៊ុណ្ណារិទ្ធ**។ ផ្លាកយីហោរបស់គេនៅពេលនោះ គឺ, *"ជាងគំនូរ "*,ដែលដំបូងប្រជាជន មានការយល់ ច្រឡំ។ បន្ទាប់មក អតិថិជនបានយល់ថា ពួកគេចេះគូរផ្ទាំងគំនូរផ្លាក យីហោ ដែលធ្វើឲ្យមុខរបររបស់គេទទួលបានជោគជ័យ។

ក្រោយពីចំណាយពេលមួយរយៈពេលខ្លីនៅភ្នំពេញមក លោក **សុខឃាង** ក៏បានវិលត្រឡប់មកខេត្តក្រចេះវិញ។ពេលលោក **សុខឃាង** ទៅភ្នំពេញនោះ លោក **ប៊ុណ្ណារិទ្ធ**ក៏បានចាប់ផ្តើមមុខរបរនេះបន្តទៅទៀត រីឯលោកសុខឃាងពេលត្រឡប់មកក្រចេះវិញ ក៏បានបើកហាងគូររូប ឈ្មោះជក់រចនានេះ ឡើងវិញ។ពួកគេទាំងពីរនាក់ នៅតែជាមិត្ត នឹងគ្នា ដដែល ហើយតែងតែខ្ចី សម្ភារៈគូររូបពីគ្នាទៅវិញទៅមក នៅពេលដែល របស់ដែលគេកុម្ម៉ង់ពីភ្នំពេញមិនទាន់មកដល់។

លោក សុខឃាង គូររូបបានពី បីទៅ បួន ផ្ទាំងក្នុងមួយខែ។ ដែល រូបភាគច្រើន គឺជាផ្ទាំងគំនូរផ្លាកយីហោហាងជួសជុលម៉ូតូ និង ហាង កែសម្ផស្ស។ លោកក៏បានគូរជាផ្ទាំងគំនូរផ្លាក សញ្ញានានា សម្រាប់ រដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាលផងដែរ ហើយជាមួយគ្នានោះ ក៏មាន ម៉ូយខ្លះៗមកពីខេត្ត ស្ទឹងត្រែង រតនគីរី និង មណ្ឌលគីរី។

ឥឡូវនេះ លោក សុខឃាងមានម៉ាស៊ីនព្រីនខ្នាតធំមួយគ្រឿង ហើយ ការគូរគំនូរផ្លាកយីហោ គឺតិចជាងមុន។ លោកបានប្រាប់ខ្ញុំថា: *"មុនពេលមានម៉ាស៊ីនព្រីន, អតិថិជនយល់ព្រមទទួលយកនូវអ្វី ដែលខ្ញុំ បានគូរឲ្យគេ តែពេលនេះ ពួកគេចង់បានភាពជាក់លាក់ដែល ចេញពី ម៉ាស៊ីនព្រីនធំ"* ។ លោក **សុខឃាង** ចូលចិត្តផ្ទាំងគំនូរដែលគូរ ដោយដៃជាង តែគាត់ដឹងថាគាត់ត្រូវតែ ធ្វើតាមតម្រូវការរបស់ អតិថិជន របស់ គាត់។

លោក **សុខឃាង**និយាយថា លោកនឹងមិនឈប់គូររូបទេ។ លោក គូររូបសិល្បៈផ្ទាល់ខ្លួន នៅពេលទំនេរ។លោករង់ចាំមើល ទេព កោសល្យ របស់កូនប្រុសទាំងពីររបស់លោក មុននឹងលោក សម្រេច ចិត្ត បង្រៀនជំនាញ គូររូបនេះដល់ពួកគេ។

លោកហាក់ដូចជាមានភាពប្រយត្ន័ប្រយែងចំពោះអនាគតផ្ទាំងគំនូរផ្លាកយីហោដែលគូរដោយដៃ និង អ្នកដែលបានគូរវា។

ទំព័រ 41

## ការរចនាគ្របសៀវភៅ

ជាងគំនូរសាយ **សុខឃាង** ត្រូវបានគេផ្តល់ ជាអត្ថបទ សម្រាប់ គូរផ្លាកយីហោ រួចហើយ លោកបានធ្វើជារូបគំនូរព្រាងចំនួនពីរ មុននឹង ចាប់ផ្តើមគូរ រូបភាពចុងក្រោយនេះ។ នេះគឺជាផ្ទាំងគំនូរ ដែលគូរ នៅលើស្មោរ ដោយផាត់ពណ៌នៅផ្ទៃខាងក្រោយ និង សរសេរអក្សរ ដោយប្រើ ថ្នាំប្រេង។

ផ្ទាំងគំនូរផ្លាកយីហោគូរដោយដៃ ក្នុង ខេត្តក្រចេះ

ទំព័រ 42-3

គុគូរគំនូរមួយដោយប្រើកំប៉ុងស្រាបៀរ។

ថ្នាំ ពណ៌ដែលបានប្រើសម្រាប់ផាត់ផ្ទៃខាងក្រោយ។
លោក**សាយ សុខឃាជ** កំពុងបង្ហើយការងារ។

ទំព័រ 45

# ការស្គាល់ប្រទេសកម្ពុជាតាមរយៈផ្ទាំងគំនូរផ្លាកយីហោ

*"ផ្លាកយីហោទាំងនេះ គឺជាផ្នែកមួយនៃវប្បធម៌ខ្មែរ"*
លោក **អាចាយ ស្ទីវែ** (Arjay Stevens ) ជាអ្នកថតរូប

ក្នុងនាមជាជនបរទេសមួយរូប ដែលកំពុងរស់នៅ និង ធ្វើការក្នុង ប្រទេសកម្ពុជាអស់រយៈពេល ពីរឆ្នាំហើយនោះ ខ្ញុំបានប្រើប្រាស់ ផ្លាក យីហោដែលគូរដោយដៃ ដើម្បីឆ្លុះបញ្ចាំងលើការយល់ដឹងរបស់ខ្ញុំ អំពី ប្រទេស និង ប្រជាជនកម្ពុជា។នៅក្នុងជំពូកទាំងនេះ ខ្ញុំនឹងចែករំលែក នូវការឆ្លុះបញ្ចាំងនេះ និងសូមណែនាំជូននូវរូបថតមួយចំនួនភ្ជាប់ មក ជាមួយ។

ខ្ញុំបានប្រើប្រាស់ផ្ទាំងគំនូរផ្លាកយីហោនានាដើម្បីប្រៀបធៀបប្រទេសកម្ពុជា, ប្រជាជនកម្ពុជា វប្បធម៌របស់ប្រទេសកម្ពុជា ជាមួយ នឹង ប្រទេសរបស់ខ្ញុំផ្ទាល់។ លើភាពជាក់ស្តែង គឺមានភាពខុសគ្នា ប៉ុន្តែបើសម្លឹងមើលឲ្យបានស៊ីជម្រៅនោះ នឹងបង្ហាញឲ្យឃើញនូវលក្ខណៈ ស្រដៀង គ្នាច្រើន។

ភាពខុសគ្នារួមមាន ឧស្សាហកម្មសម្លៀកបំពាក់ និង កសិកម្ម ដ៏របស់ប្រទេសកម្ពុជា ប្រៀបធៀបនឹងវិស័យសេវា គឺមានលក្ខណៈ ខ្ពស់ជាងសេដ្ឋកិច្ចអង់គ្លេស។ ទិដ្ឋភាពវប្បធម៌ក៏ដូច្នេះដែរ ដូចជាការយល់ ឃើញខុសគ្នាអំពីសម្រស់ និង ការចូលចិត្តចំណីអាហារ។ ផ្លាកប៉ាណូ របស់រដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលក៏បង្ហាញនូវភាពខុសគ្នា ក្នុងប្រវត្តិសាស្ត្រ រវាងប្រទេសកម្ពុជា និង ប្រទេសរបស់ខ្ញុំបាទដែរ។

ភាពស្រដៀងគ្នាមួយរវាងប្រទេសនានានោះគឺ ចំណង់ចង់មាន សម្រស់ស្អាត ដូចដែលបានបង្ហាញនៅក្នុងផ្លាកយីហោហាងកែសម្ផស្ស និង ហាងកាត់សក់ជាច្រើន។ការហូបឆ្ងាញ់ និង ពិធីជប់លៀង ក៏ត្រូវបាន ឲ្យតម្លៃនៅក្នុងវប្បធម៌របស់ប្រទេសនិមួយៗដែរ ឧទាហរណ៍ ផ្ទាំងយីហោ ទីផ្សារលក់ចេញចំណីអាហារ និង អ្នកផ្តល់ការកំសាន្តសប្បាយនានា។ ការប្រើប្រាស់ទូរសព្ទ័ដៃគឺជាទំនោរអន្តរជាតិមួយ ហើយ ឋានៈនៃការប្រើប្រាស់រថយន្ត និង ម៉ូតូ ក៏ដូច្នេះដែរ។

ជាជនបរទេសមួយរូប ខ្ញុំមិនធ្លាប់បានយល់ពីប្រទេសកម្ពុជា និង ប្រជាជនកម្ពុជា ឲ្យបានពិតប្រាកដនោះ ឡើយ ប៉ុន្តែផ្ទាំងគំនូរផ្លាកយីហោ ទាំងនេះ បានជួយដល់ខ្ញុំឲ្យយល់បានសមស្រប ទៅតាមការរៀនសូត្រ របស់ខ្ញុំ។ ថ្វីបើមានភាពខុសគ្នាមួយចំនួន តែតាមការពិតវប្បធម៌ របស់ យើង គឺមានភាពខិតជិតគ្នាជាងអ្វីដែលយើងមើលឃើញ ហើយការ ចងក្រងជាសៀវភៅនេះឡើង បានជួយ ឲ្យខ្ញុំរកឃើញនូវភាពស្រដៀងគ្នា នោះ។ ខ្ញុំបាទសង្ឃឹមថា លោកអ្នកក៏នឹងមើលឃើញ នូវអ្វីមួយថែមទៀត អំពីប្រទេសរបស់លោកអ្នកផ្ទាល់ នៅក្នុងទំព័របន្តបន្ទាប់ទៅ ទៀតនេះ។

ទំព័រ 49

## អក្សរខ្មែរ

មានតែផ្លាកយីហោពីរប៉ុណ្ណោះនៅក្នុងសៀវភៅនេះ ដែល មិន មាន សរសេរអក្សរ [38-9], ហាងកែសម្ផស្ស មានសរសេរអក្សរ ច្រើន ជាង គេ [22],និង ហាងកាត់សក់មានសរសេរអក្សរតិចជាងគេ [72-3, 81].។

សំណេរអក្សរខ្មែរមានលក្ខណៈស្រស់ស្អាត។ វាជាភាសាមួយ ដែលពិបាករៀន ពីព្រោះវាមានតួអក្សរ និង និម្មិតសញ្ញាច្រើន ជាង អង់គ្លេស ។

ការសរសេរអក្សរនៅលើផ្លាកយីហោគឺជាធម្មតា មានមួយជួរ។ អក្សរស្រមោល [48],អក្សរគ្មានស្រមោល [130]អក្សរដែលមាន ពណ៌ ស្លេក នៅខាងក្នុង ត្រូវបានប្រើដើម្បីតុបតែង ។

ការសរសេរអក្សរនៅលើផ្លាកយីហោនានា បានជួយបន្ថែម ពណ៌ ចម្រុះដល់ដងផ្លូវនានារបស់ប្រជាជនកម្ពុជា។ ការប្រើពណ៌បញ្ចូលគ្នា ភាគ ច្រើនគឺ ពណ៌ខៀវ និង ស ប៉ុន្តែពណ៌ផ្សេងៗទៀតក៏មានប្រើផងដែរ។ មាន ផ្លាកយីហោមួយ ប្រើពណ៌ចាំងដូចមាស [95].។

ទំព័រ 59

## ពត៌មានសាធារណៈ

ផ្ទាំងគំនូរពតិមានសាធារណៈ ដែលរួមមាន ការណែនាំ ឲ្យ កុមារ ទៅចាក់ថ្នាំបង្ការ [65]រហូតទៅដល់ការរក្សាអនាម័យភូមិឋាន [58]។

មានផ្លាកផ្ទាំងគំនូរមួយ[64]ដែលជាការរំលឹកដល់ប្រវត្តិនៃ អំពើ ឃោរឃៅនៅក្នុងប្រទេសកម្ពុជា។ផ្ទាំងគំនូររបៀបនេះ ត្រូវបាន គេមើល ឃើញ នៅក្នុងទីក្រុងដទៃៗទៀតក្នុងប្រទេសកម្ពុជាផងដែរ ដែល ផ្ទាំងគំនូររបៀបនេះ ត្រូវបាន គេផលិតនៅកន្លែង មួយរួច ហើយចែកចាយ នៅ ទូទាំងប្រទេស។

ផ្ទាំងគំនូរមួយផ្សេងទៀត[68] បានហាមមិនឲ្យបញ្ជូនកុមារៗ ទៅ ធ្វើការ នៅឆ្ងាយពីផ្ទះ។ ដែលនេះគឺព្រោះតែ ការជួញដូរ មនុស្ស នៅតែ ជា បញ្ហា នៅតំបន់អាស៊ីអគ្នេយ៍នៅឡើយ។ ផ្ទាំងមួយដែលទំនើបដែរនោះ គឺ ការផ្សព្វផ្សាយអំពីការងារអភិរក្សសត្វផ្សោតដ៏កម្រ ដែលមាននៅក្នុងខេត្តក្រចេះ [62] ។

ទំព័រ 71

## ហាងកែសម្ផស្ស និង កាត់សក់

ផ្លាកយីហោហាងកែសម្ផស្ស ធម្មតាមានរាយឈ្មោះ សេវា កម្ម នានា ដែលធ្វើឲ្យស្បែកស។ ចំណុចនេះគឺធ្វើឲ្យស្ត្រីដែលមក ពីបណ្តា ប្រទេស ដែលខំចំណាយលុយធ្វើឲ្យ ស្បែកខ្មៅ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ចំណុចមួយ ដែលកាន់ តែ ស្រដៀង គ្នាថែមទៀតទៅ នឹងបណ្តាប្រទេសដទៃនោះគឺ ការធ្វើឲ្យ សក់ត្រង់ ឬ សក់រួញ។ ចំណុច នេះ បង្ហាញពីឧស្សាហកម្មសម្រស់ ដែល អាស្រ័យ ទៅលើ ទស្សនៈ ដែលថា អ្វីដែលខុសពីធម្មជាតិ គឺមើល ទៅស្អាតជាង។ ចំណុច ស្រដៀងគ្នាមួយទៀតនោះ គឺ អាពាហ៍ពិពាហ៍ ដែល បណ្តាប្រទេសជាច្រើន គេបានបំលែងរូបសម្រស់កូនក្រមុំ តែមួយ ប៉ព្រិចភ្នែក។

ផ្លាកយីហោហាងធ្វើសក់មួយ គឺមានសភាពចាស់ ជាងផ្លាក ដទៃ[76-7]។ ផ្លាកយីហោ នោះត្រូវបាន គេគូរនៅឆ្នាំ ១៩៩៨ ហើយម៉ូដសក់ ដែល បង្ហាញនៅក្នុងផ្លាកយីហោនោះ នៅមិនទាន់សម័យ ឡើយ។ ផ្លាកមួយទៀត ដែលមានសភាពខុសពីធម្មតាដែរនោះ [78] មាន រៀបរាប់ ពីសេវាធ្វើសក់ទាំងបុរស និង ស្ត្រី។

ផ្ទាំងគំនូរផ្លាកយីហោគូរដោយដៃ ក្នុង ខេត្តក្រចេះ

ផ្ទាំងគំនូរផ្លាកយីហោកាត់សក់បង្ហាញពីសកម្មភាព កំពុង កាត់ សក់ ឬ រូបភាពពេលកាត់សក់រួច។ ផ្ទាំងគំនូរផ្លាក យីហោ កាត់សក់ មាន អក្សរតិចជាងផ្ទាំងគំនូរផ្លាកយីហោហាងកែសម្ផស្ស។ ចំណែក រូបវិញ គឺភាគច្រើនជារូបបុរស តែមានហាងកាត់សក់មួយ មាន រូបគំនូរ ក្មេង ប្រុស ម្នាក់ទៅវិញ [85].។

ទំព័រ 87

## សុខភាព

បន្ទប់ម៉ាស្សាខ្មែរខ្លះ តែងមានផ្តល់សេវា 'បន្ថែម'សម្រាប់បុរសៗ។ នៅកន្លែងម៉ាស្សាតាមផ្ទះ [86-7] មានផ្តល់សេវាព្យាបាលដោយស្ពំ កោស ជប់ ដែលសេវាទាំងនេះ មើលទៅដូចជាមានការឈឺចាប់ និង បន្សល់នូវស្នាមលើស្បែកទៀតផង។

រូបភាពនៅ លើផ្លាកយីហោពេទ្យធ្មេញវិញ ក៏មើលទៅ ហាក់ ដូចជា មានការឈឺចាប់ផងដែរ[88-9]។ វាធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលដែលគេ ទទួល បានអ្នកជម្ងឺ។មានផ្លាកយីហោរបស់ពេទ្យធ្មេញមួយដែលបង្ហាញពីផលប្រយោជន៍ ក្នុងការមកកាន់ពេទ្យធ្មេញ គឺធ្មេញថែងចាំង ជំនួសឲ្យ សញ្ញា ឈឺ ធ្មេញ។

ទំព័រ 91

## ចំណីអាហារ និង សិល្បៈ

ប្រជាជនខ្មែរចូលចិត្តបាយ ហើយពាក្យថាហូបបាយ គឺមិនមែន ហូប តែបាយនោះទេ។ មនុស្សជាច្រើនហូបចំណីចំណុកនៅក្រៅផ្ទះ ហើយ នៅក្នុងខេត្តក្រចេះ មានតូបលក់ម្ហូបអាហារ ជាច្រើននៅតាម មាត់ទន្លេ ដែលលក់ម្ហូបអាហារ ក្នុងស្រុក។ផ្លាកយីហោ មួយ[90]ក្នុង ចំណោម ផ្លាកយីហោលក់ម្ហូបអាហារទាំងនេះ គឺ ផ្លាកយីហោលក់ ក្រឡាន ក្រូចថ្លុងកោះទ្រង់ និង ណែម។

ផ្លាកយីហោមួយទៀត[94]បង្ហាញពីបបរ និង ពងទាកូនដ៏មាន ប្រជាប្រិយ៍ភាព។សម្រាប់ជនបរទេស, ពងទាកូនគឺជាអាហារ មួយបែប ដ៏សែន ប្លែក ចំណែកអាពីងបំពងមកពីខេត្តកំពង់ចាម ក៏ដូច្នេះដែរ។

ប្រជាជនកម្ពុជាចូលចិត្តពិធីជប់លៀង ដោយមានការរាំច្រៀង ជាមួយ នឹងតន្ត្រីដែលមាន សម្លេងឮខ្លាំងៗ។ក្រុមតន្ត្រី ប្រើប្រាស់ ផ្លាកយីហោដែលគូរដោយដៃ ដើម្បីផ្សព្វផ្សាយ ហើយដោយឡែក នៅ ខេត្តក្រចេះ គឺមានក្រុមតន្ត្រីតារា [92] និង ក្រុមតន្ត្រី សូរិយា [93]។ រូបសញ្ញាទន្សយស នៅលើផ្លាកយីហោរបស់ក្រុមតន្ត្រីសូរិយាគឺជានិមិត្តរូប នៃ សំណាងល្អ [សូមមើល 26].។

ផ្លាកយីហោរបស់ក្រុមតន្ត្រីទាំងពីរ ត្រូវបានជាងគំនូរម្នាក់ ឈ្មោះ ឆៃ ជាអ្នកគូរ។ ផ្លាកយីហោទាំងពីរនេះ មានរូបស្តូរស្រដៀងគ្នា។ លោក ឆៃ ក៏បានគូររូបផ្លាកយីហោផ្សព្វផ្សាយពីមុខរបររបស់លោកផងដែរ [95] ។

ទំព័រ 97

## កាត់ដេរ

សម្លៀកបំពាក់ គឺជាទំនិញនាំចេញដ៏សំខាន់មួយរបស់ប្រទេស កម្ពុជា។ជំនាញនៃមុខជំនួញនេះ បានរាលដាលចេញ ពីឧស្សាហកម្ម កណ្តាលក្រុ ងភ្នំពេញ។ តូបកាត់ដេរជាច្រើនត្រូវបានគេប្រទះឃើញ ស្ទើរ គ្រប់កន្លែងក្នុងខេត្តក្រចេះ។ ភាគច្រើនវាជាការងាររបស់ស្ត្រី ប៉ុន្តែក៏មាន បុរស ចូលរួមផងដែរ។ ផ្លាកយីហោតែងតែមានរូបម៉ាស៊ីនដេរ ឬ កន្ត្រៃ [96-101]។

ទំព័រ 103

## ការដឹកជញ្ជូន

ម៉ូតូ គឺជាមធ្យោបាយធ្វើដំណើរដ៏មានប្រជាប្រិយ៍ភាព។ ជន បរទេស មានការភ្ញាក់ផ្អើល ដោយសារឃើញថាគេអាចជិះ បានច្រើន នាក់នៅលើម៉ូតូមួយគ្រឿង ហើយជារឿយៗ គឺគ្មានពាក់មួក សុវត្ថិភាព ទៀត។ ម៉ូតូក៏ត្រូវបាន កែឆ្នៃសម្រាប់ដឹក ទំនិញច្រើនប្រភេទ ខុសៗ គ្នាផងដែរ។

ជាងជួសជុលម៉ាស៊ីន អាចរកបានតាមរយៈការស្វែងរកផ្លាកដែល គូរដោយដៃមានរូបម៉ូតូ ឬ សំបកកង់ដែលគេចងព្យួរ [106-8]។ រូបភាពជាទូទៅគឺជារូបម៉ូតូដ៏មានប្រជាប្រិយ៍ភាពបំផុតរបស់កម្ពុជា គឺ ហុងដាឌ្រីម [108]ជួនកាលក៏មានរូបម៉ូតូផ្សេងដែរ ដូចជា ហុងដាវ៉េវ [104] ឬ ស៊ុយហ្ស៊ុយគីវីវ៉ា [20].ផ្លាកយីហោទាំងនេះ បង្ហាញថាម៉ូតូជប៉ុន គឺ មានច្រើនជាងគេនៅក្នុងប្រទេសកម្ពុជា ចំណែករថយន្តវិញ ក៏ដូចគ្នាដែរ។

រថយន្តដែលមានប្រជាប្រិយ៍ភាពបំផុតគឺ តូយ៉ូតាកាមរី[105] ឡង់គ្រីសរ័ ជាពិសេស លុចស៊ីស [109 *ខាងក្រោមឆ្វេង*] គឺជានិម្មិតរូប ទ្រព្យសម្បត្តិ និង អំណាច។ មានឋានានុក្រម យ៉ាងច្បាស់លាស់ នៅ តាមផ្លូវថ្នល់ដោយផ្អែកលើទំហំយានយន្ត។ កង់គឺស្ថិតនៅក្រោម គេក្នុង ឋានានុក្រម។ចំណែកអ្នកដែល នៅលើគេក្នុងឋានានុក្រម គឺ គោ។ អ្នកបើកបរ ទាំងអស់ត្រូវតែឈប់ដើម្បីឲ្យគោឆ្លងកាត់ ព្រោះពួកវាមិន ទៅណាទេរហូតទាល់តែពួកវាត្រៀមខ្លួនបានត្រឹមត្រូវដើម្បីចេញពីផ្លូវ។

ជនជាតិខ្មែរចូលចិត្តថែរក្សាយានយន្តរបស់ខ្លួនឲ្យស្អាត។ ការលាងឡាន គឺជារឿងសំខាន់ ពីព្រោះតែភក់និង ធូលីនៅតាម ផ្លូវរបស់ ប្រទេសកម្ពុជា។ សម្រាប់ជនបរទេស រូបគំនូរអ្នកលាងឡាន នៅក្នុង ផ្លាកយីហោ មើលទៅដូចជាអ្នកពន្លត់អគ្គីភ័យ[102]។

ទំព័រ 113

## សត្វពាហនៈ

មានផ្លាកយីហោជាច្រើនសម្រាប់មុខជំនួញទាក់ទងនឹងការគាំទ្រដល់វិស័យកសិកម្ម នៅក្នុងប្រទេសកម្ពុជា។ ផ្នែកខ្លះនៅក្នុងចំណុចនេះ ធ្វើឲ្យជនបរទេស ខ្លះមានការភ្ញាក់ផ្អើល ឧទាហរណ៍ ផ្លាកយីហោ ផ្សព្វផ្សាយពីសេវាបង្កាត់ពូជ ដូចជា បង្កាត់ពូជគោ [118]។ ផ្លាកយីហោមួយផ្សេងទៀត សម្រាប់សត្វជ្រូក ក៏បង្ហាញនូវផ្នែកដ៏សំខាន់មួយអំពីការផ្តល់សេវាជ្រូកបាសម្រាប់បង្កាត់ពូជផងដែរ [119]។

ផ្លាកយីហោមួយផ្សេងទៀតដែលមានរូបសត្វ ផ្សព្វផ្សាយពីចំណីសត្វ និង ថ្នាំព្យាបាលសត្វ [117] និងបម្រាមដែលមានរូបឆ្កែយាមផ្ទះ [112, 114]។ ឆ្កែតែងតែបង្កើតជាសម្លេងរំខាននៅពេលយប់ ហើយជួនកាលលំបាក ក្នុងការដេកឲ្យបានលក់ស្កប់ស្កល់ខ្លាំងណាស់ នៅពេលយប់នៅខេត្តក្រចេះ។

ផ្លាកយីហោរូបឆ្កែមួយផ្សេងទៀត [115]បង្ហាញពីអាហារដែលមិនមាននៅឯប្រទេសរបស់ជនបរទេស ។ តែទោះជាយ៉ាងណាក្តី ,សាច់ខ្វៃ[116] គឺជាសាច់ដែលមាន ប្រជាប្រិយ៍ភាពនៅក្រៅប្រទេសកម្ពុជា។នៅ ក្នុងផ្ទាំងគំនូរផ្លាកយីហោនេះ មើលទៅហាក់ដូចជាជ្រូកកំពុងព្យាយាមរត់គេច ដោយប្រឹងហើរចេញពីកន្លែងខ្វៃជ្រូកអញ្ចឹង។

ផ្ទាំងគំនូរផ្លាកយីហោគូរដោយដៃ ក្នុង ខេត្តក្រចេះ

ទំព័រ 121

## បច្ចេកវិទ្យា

បរិក្ខារអគ្គិសនីជាច្រើនប្រភេទ អាចជួសជុលនៅខេត្តក្រចេះបាន [122-7], ដោយរួមទាំងក្បាលចាក់វីស៊ីឌី [123]។បរិក្ខារទាំងនេះ ត្រូវបានប្រើដើម្បីចាក់នូវបទចម្រៀងថ្មីៗ ឬ សាច់រឿងអូប៉េរ៉ា ដូចដែលគេធ្លាប់ចាក់ខ្លាំងៗនៅតាមរថយន្តក្រុងជាដើម។ ការកំសាន្តដ៏មានប្រជាប្រិយ៍ភាពផ្សេងៗទៀត មានដូចជា ភាពយន្តគំនូរជីវចល ផ្ទារ និង កណ្តុរ និង រឿងក្បាច់គុនចិន។

ប្រជាជនកម្ពុជាភាគច្រើន ប្រើទូរសព្ទ័ដៃ ជំនួសឲ្យទូរសព្ទ័ខ្សែ [130-1]។វាពិតជាមានការចម្លែកក្នុងចិត្តជំពោះជនបរទេស ដែលថាប្រជាជនកម្ពុជា ប្រើទូរសព្ទ័ច្រើនប្រពន្ធ័ខុសៗគ្នា ពីព្រោះយើងជាជនបរទេសជាធម្មតាប្រើតែទូរសព្ទ័ម្នាក់តែមួយប្រពន្ធ័ប៉ុណ្ណោះ។

វាក៏ជាការភ្ញាក់ផ្អើលមួយចំពោះជនបរទេសផងដែរ ដែល ជន ជាតិ ខ្មែរ លើកទូរសព្ទ័នៅពេលកំពុងប្រជុំ ឬ នៅពេល កំពុង ធ្វើបទ បង្ហាញនានា។ ចំណុចនេះ ជាការពិបាកនឹងសម្របតាម ហើយត្រូវបាន គិតថា មិនមានភាព គួរសម នៅបណ្តាប្រទេសជាច្រើន។

ទំព័រ 133

## នៅតាមដងផ្លូវក្នុងប្រទេសកម្ពុជា

ដោយ *រ៉ូប៊ឺត ចញន័រ*(Robert Joiner)

នៅក្នុងកំឡុងពេល នៃ ការធ្វើដំណើរមួយពីភ្នំពេញ ទៅកាន់ ខេត្ត កំពង់ចាម, ក្រុមភ្ញៀវរបស់ខ្ញុំដែលមកពីបរទេស មានការភ្ញាក់ ផ្អើល យ៉ាងខ្លាំង ជាមួយនឹងចំនួន ព្រមទាំង រូបរាងប្លែកៗគ្នា នៃផ្លាកយីហោគូរដោយដៃ។ការភ្ញាក់ផ្អើលនឹងទិដ្ឋភាពថ្មីៗ ជាពិសេសគឺផ្ទាំងគំនូរចាស់ៗដ៏គួរឲ្យចាប់ចិត្ត បានក្លាយជាទស្សនីយភាព ល្វេន មួយសម្រាប់ពួកយើង ពេលពួកយើងបាន ធ្វើដំណើរដល់ កន្លែងមួយ នៃចរាចរជនបទ ដ៏សប្បាយដែលមានរទេះគោ, ម៉ូតូដឹក ឥវ៉ាន់សំពីងសំពោង និង ឡានកាមីញ៉ុងចាស់ៗ ជាដើម។

ប៉ុន្តែចេញពីទស្សនីយភាពល្វេននេះទៅ រូបភាពនៃភាពធ្ងន់ធ្ងរ មួយ បាន ផុសឡើង។ នេះគឺប្រាកដណាស់ថា ជាសិល្ប: ដែលកំពុង តែស្លាប់បាត់បង់ទៅវិញជាបណ្តើរៗ ពោលគឺ បច្ចេកវិទ្យាជឿនលឿន, វិធីបោះពុម្ពឌីជីថលដែលរហ័ស និង មានតម្លៃថោក ប្រាកដជាមានន័យថា ជាទីបញ្ចប់នៃ ស្នាដៃសិល្ប: ខ្មែរទាំងនេះហើយ។ ដោយបានគិតថា គេគួរតែថែរក្សា នូវរូបភាពទាំងនេះ ធ្វើជាឯកសារប្រវត្តិសាស្ត្រ សម្រាប់ អ្នកដទៃ បាន សប្បាយ នោះ គឺជាអ្វីដែលបានធ្វើឲ្យខ្ញុំ បានសរសេរ ជា សៀវភៅមានចំណងជើងថា *"តើអ្នកបាន ឃើញវត្ថុមួយនេះទេ? ស្លាក យីហោ សិល្ប: នៅក្នុងជីវិតខ្មែរ ឬ Did you see this one? Sign Art in Cambodian Life".*

ឥឡូវនេះ រយ:ពេលប្រាំឆ្នាំបានកន្លងផុតទៅហើយ ចាប់តាំងពី ខ្ញុំបាន កត់ត្រានូវស្នាដៃសិល្ប:ទាំងនោះ និង បានបោះពុម្ពជាសៀវភៅ។ ខ្ញុំមានសេចក្តីរីករាយយ៉ាងខ្លាំង ដោយបានដឹងថា លោក សាម កំពុង តែ បន្តនូវដំណើររបស់ខ្ញុំ ក្នុងការស្វែងរក និង បន្ថែមទៅលើ កិច្ចការ របស់ លោកផ្ទាល់ ចំពោះអ្វី ដែលខ្ញុំបានចាប់ផ្តើមប្រមូលជាមួយនឹង រូបថតស្លាក យីហោនានា ដែលមានភាពទាក់ទាញចំពោះខ្ញុំ។

រឿងមួយដែលប្រាកដនោះ គឺសិល្ប: នៃការ ផ្សព្វផ្សាយ ពាណិជ្ជកម្ម ដែលជាផ្នែកមួយដ៏សំខាន់នៃ ជីវិតរស់នៅប្រចាំ ថ្ងៃនៅក្នុង ប្រទេសកម្ពុជានោះ នឹងមិនស្ថិតនៅក្នុងទម្រង់ដើមជារៀងរហូតឡើយ។ ការបន្ថែម របស់លោក សាម ទៅលើការសម្រិតសម្រាំងរបស់ខ្ញុំ នឹង បន្ថែម កម្លាំងដល់ ការប្រមូលផ្តុំនូវឯកសារទាំងនោះ សម្រាប់បងប្អូន ទាំងអស់គ្នាបានមើល ពីផ្នែកមួយនៃចរិតលក្ខណ: នៃ ជីវិតរស់នៅ ប្រចាំថ្ងៃ របស់ ប្រជាជនកម្ពុជា ភាគច្រើន។